**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន** | **ក្រសួងទេសចរណ៍**

# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពី
# លទ្ធផលនៃការផ្សព្វផ្សាយពី
# «ស្ថានភាពទេសចរណ៍កម្ពុជា នៅក្នុងបរិបទតំបន់ និងពិភពលោកដែលមានភាពមិនប្រាកដប្រជា ប្រែប្រួលឆាប់រហ័ស និងព័ត៌មានក្លែងក្លាយ»

នៅរសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ ក្រសួងព័ត៌មាន និងក្រសួងទេសចរណ៍បានសហការរៀបចំពិធីផ្សព្វផ្សាយពី «**ស្ថានភាពទេសចរណ៍កម្ពុជា នៅក្នុងបរិបទតំបន់ និងពិភពលោកដែលមានភាពមិនប្រាកដប្រជា ប្រែប្រួលឆាប់រហ័ស និងព័ត៌មានក្លែងក្លាយ**» ក្នុងគោលបំណងដើម្បីលើកកម្ពស់យុទ្ធនាការជំរុញទេសចរណ៍ ដោយការកសាងទំនុកចិត្ត និងទាក់ទាញភ្ញៀវទេសចរពីជុំវិញពិភពលោកមកទស្សនាកម្ពុជា តាមរយៈយុទ្ធនាការប្រឆាំងព័ត៌មានក្លែងក្លាយ។

ពិធីផ្សព្វផ្សាយនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អមដោយថ្នាក់ដឹកនាំនៃក្រសួងទាំងពីរ និងអង្គភាពសារព័ត៌មាន សមាគមអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានចំនួនប្រមាណ៤០០នាក់។

តាមរយៈពិធីផ្សព្វផ្សាយនេះ ក្រសួងព័ត៌មានបានបញ្ជាក់ពីតួនាទីក្នុងការចូលរួមលើកកម្ពស់វិស័យទេសចរណ៍កម្ពុជា ដោយឈរលើមូលដ្ឋាននេះ៖

១. ការការពារបរិយាកាសព័ត៌មានឱ្យស្អាតស្អំ ដើម្បីសន្តិភាព និងស្ថិរភាពសង្គមកម្ពុជា

២. ការជំរុញការផ្សព្វផ្សាយព័ត៌មានពិត ដើម្បីកសាងទំនុកចិត្តអន្តរជាតិ ក៏ដូចជាទាក់ទាញការវិនិយោគនិងទេសចរណ៍មកកម្ពុជា

៣. ការលើកកម្ពស់ការទូតព័ត៌មានតាមរយៈប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋម្នាក់ដើរតួនាទីជាអ្នកទទួលព័ត៌មាន និងជាអ្នកផ្សព្វផ្សាយព័ត៌មាន។ ដូច្នេះរាល់ការចែករំលែក គឺមានសក្តានុពលក្នុងការបង្ហាញរូបភាពកម្ពុជាទៅកាន់ពិភពលោក

៤. ការបំលែងការប្រឆាំងព័ត៌មានក្លែងក្លាយ ទៅជាយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជា ដោយត្រូវជំរុញការកសាងកិត្យានុភាព និងកេរ្តិ៍ឈ្មោះកម្ពុជា (Branding Cambodia) តាមរយៈការផ្សព្វផ្សាយព័ត៌មានពិតទៅកាន់ពិភពលោក អំពីវប្បធម៌ អរិយធម៌ដ៏អស្ចារ្យ និងសម្បត្តិធម្មជាតិដ៏ស្រស់ត្រកាល ដែលជាកម្លាំងទាក់ទាញភ្ញៀវទេសចរ និងវិនិយោគ

៥. ព័ត៌មានពិតថ្ងៃនេះ គឺជាកំណើនសេដ្ឋកិច្ច និងទេសចរណ៍ថ្ងៃស្អែក ពីព្រោះភាពជឿជាក់លើព័ត៌មាន គឺជាការការពារឱកាសការងារ ការពារចំណូលពីទេសចរណ៍ និងការពារកំណើនសេដ្ឋកិច្ចជាតិ។

៦. ទន្ទឹមនេះដែរ ក្រសួងព័ត៌មានសូមអំពាវនាវឱ្យសាធារណជនទាំងអស់ចូលរួមបង្កើត «**វប្បធម៌ព័ត៌មានទទួលខុសត្រូវ**» តាមរយៈ៖ **(១)** កុំចែករំលែកព័ត៌មានដែលមិនប្រាកដ **(២)** កុំឱ្យព័ត៌មានក្លែងក្លាយបំផ្លាញមុខមាត់ និងសេដ្ឋកិច្ចកម្ពុជា **(៣)** ចូលរួមផ្សព្វផ្សាយភាពពិត និងភាពស្រស់ស្អាត សក្តានុពលទេសចរណ៍ និងកាលានុវត្តភាពវិនិយោគរបស់ប្រទេសយើង។

ជាមួយគ្នានេះដែរ ក្រសួងទេសចរណ៍ក៏បានបង្ហាញពីលទ្ធផលនៃការរៀបចំព្រឹត្តិការណ៍បុណ្យទន្លេលើកទី១០ និងស្ថានភាពទេសចរណ៍កម្ពុជា ស្ថិតក្នុងកាលៈទេសៈប្រឈមខ្ពស់ ដែលការណ៍នេះចាំបាច់ត្រូវដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះដើម្បីលើកកម្ពស់វិស័យទេសចរណ៍ ក្នុងឆ្នាំ២០២៦ ដោយត្រូវ៖

១. ពង្រឹងយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស ឱ្យចំគោលដៅ ព្រមទាំងការលើកកម្ពស់កិត្តិនាមកម្ពុជានៅលើឆាកអន្តរជាតិ

២. ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ឱ្យកាន់តែទូលំទូលាយ

៣. សម្រួលការធ្វើដំណើរចូល-ចេញប្រទេសកម្ពុជា និងជំរុញការតភ្ជាប់ការធ្វើដំណើរ

៤. ពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍

៥. អភិវឌ្ឍផលិតផលទេសចរណ៍កម្ពុជាឱ្យសម្បូរបែប និងកាន់តែមានភាពទាក់ទាញ និង

៦. ផ្សព្វផ្សាយនិងជំរុញទេសចរណ៍ក្នុងស្រុក តាមរយៈការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗ ច្នៃប្រឌិត ចម្រុះអន្តរជាតិ និងប្រកបដោយភាពទាក់ទាញនៅតាមបណ្តាខេត្ត (មួយខេត្ត មួយព្រឹត្តិការណ៍) និងព្រឹត្តិការណ៍នៅថ្នាក់ជាតិ និងអន្តរជាតិ។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រគន្លឹះទាំង៦នេះ ក្រសួងទេសចរណ៍នឹងរៀបចំយុទ្ធនាការសំខាន់ចំនួន៤ រួមមាន៖ **(១)** យុទ្ធនាការទស្សនាកម្ពុជានៅរដូវកាលបៃតង (Green Season) ចាប់ពីខែឧសភា ដល់ខែតុលា **(២)** គម្រោងសាកល្បងលើកលែងទិដ្ឋាការសម្រាប់ពលរដ្ឋចិន ក្នុងអំឡុងពេលនៃរដូវកាលបៃតង ដែលមានរយៈពេល៤ ខែ ចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៦ **(៣)** យុទ្ធនាការរដូវកាលសាមគ្គីភាព (Solidarity Season) និង **(៤)** យុទ្ធនាការផ្សព្វផ្សាយកម្ពុជា ជាគោលដៅទេសចរណ៍សុវត្ថិភាព។

តាមរយៈការផ្សព្វផ្សាយអំពី «**ស្ថានភាពទេសចរណ៍កម្ពុជា នៅក្នុងបរិបទតំបន់ និងពិភពលោក ដែលមានភាពមិនប្រាកដប្រជា ការប្រែប្រួលឆាប់រហ័ស និងព័ត៌មានក្លែងក្លាយ**» ក្រសួងព័ត៌មាន និង

ក្រសួងទេសចរណ៍សង្ឃឹមយ៉ាងមុតមាំថា សាធារណជន និងអ្នកសារព័ត៌មានទាំងអស់ នឹងចូលរួមផ្សព្វផ្សាយព័ត៌មានពិតអំពីកម្ពុជា និងទេសចរណ៍កម្ពុជា ទៅកាន់ពិភពលោកឱ្យបានកាន់តែទូលំទូលាយ ដើម្បីកសាងទំនុកចិត្តរបស់អន្តរជាតិ មកលើកម្ពុជាថា «**កម្ពុជាជាគោលដៅទេសចរណ៍សុខសុវត្ថិភាព កក់ក្ដៅ ស្អាត និងបៃតង**»។ ទន្ទឹមនេះដែរ ក្រសួងព័ត៌មានសូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប សូមធ្វើខ្លួនឱ្យក្លាយជាអ្នកការពារព័ត៌មានពិត នោះកម្ពុជានឹងក្លាយជាប្រទេសដែលមានសំឡេងខ្លាំង មានកិត្តិយស និងមានភាពទាក់ទាញកាន់តែខ្លាំងលើឆាកអន្តរជាតិ ព្រោះថា (១) ការពារព័ត៌មានពិត គឺការពារជាតិ (២) ផ្សព្វផ្សាយការពិត គឺផ្សព្វផ្សាយកម្ពុជា (៣) ព័ត៌មានពិតថ្ងៃនេះ គឺភ្ញៀវទេសចរដ៏ច្រើនថ្ងៃស្អែក។

ថ្ងៃពុធ ១៤កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦

**ក្រសួងព័ត៌មាន** **ក្រសួងទេសចរណ៍**